# រំឭកមេរៀន





# តើអ្វីខ្លះ ជាគុណតម្លៃនៃការអប់រំ ?

## ចម្លើយ

- ការអប់រំជាថ្នាលនៃការបណ្តុះបណ្តាល ( ជំនាញ សមត្ថភាព)
- ការអប់រំផ្តល់នូវចំណេះដឹងដល់យើង ( កិត្តិយស ការងារ )
- ការអប់រំផ្តល់នូវការទទួលបានការគោរពរាប់អានពីបុគ្គលដទៃ ( ឥរិយាបថ )

# តើអនក្ខរភាពបានផ្តល់ផលវិបាកអ្វីខ្លះ សង្គមជាតិ ?

## ចម្លើយ

### ចំពោះសង្គមជាតិ

- កង្វះនូវធនធានមនុស្ស
- សេដ្ឋកិច្ចសង្គមអន់ថយព្រោះអ្នកបច្ចេកទេសស្រាវជ្រាវ
- បរទេសឆក់នូវឱកាសលុបបំបាត់អត្តសញ្ញាណជាតិរបស់ខ្លួន ប្រទេសជាតិអាចធ្លាក់ក្នុងភាពអាណានិគមបរទេស ។

តើនៅសហគមន៍របស់ប្អូនៗ រស់នៅមាន
សាលារៀន មន្ទីរពេទ្យបម្រើបានគ្រប់
គ្រាន់ដែរឬទេ ?



ថ្នាក់ទី ១២

# ភូមិវិទ្យា

## ជំពូកទី២ ៖ អភិវឌ្ឍន៍ប្រជាជនមិនស្មើ

## មេរៀនទី៣៖ វិសមភាពនៃការប្រើប្រាស់សេវាមូលដ្ឋាន

បង្រៀនដោយ អ្នកគ្រូ ម៉ុក ផាណៃ ឯកទេស ៖ ភូមិវិទ្យា នៃវិទ្យាល័យព្រះស៊ីសុវត្ថិសាលារៀនជំនាន់ថ្មី

# វត្ថុបំណង



ពន្យល់បានពីនិយមន័យពាក្យសេវាសង្គម និងអ្វីខ្លះដែលស្ថិតក្នុងសេវាសង្គម



បកស្រាយបានពីគុណសម្បត្តិនៃការផ្តល់សេវាសង្គម សារប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត និងអនាម័យមូលដ្ឋាន ។



# និយមន័យ



- សេវាសង្គម : សកម្មភាពបំពេញតម្រូវការសម្រាប់សង្គម ដោយមិនបានផលិតជាសម្ភារៈប្រើប្រាស់ ។
- អត្រាមរណភាពទារក : ផលធៀបរវាងចំនួនកុមារក្រោមអាយុ 1ឆ្នាំស្លាប់ទៅនឹងកំណើតរស់ 1000 នាក់ ។
- អត្រាមរណប្រមាណមាតា : ផលធៀបរវាងចំនួនស្ត្រីស្លាប់ក្នុងមូលហេតុមានគភ៌ក្នុងកំណើតរស់ 100 000 នាក់ ។
- សក្តានុពល : ភាពសំខាន់ៗជាចម្បង ។





# លទ្ធភាពប្រើប្រាស់សេវាសង្គម

# ដូចម្តេចដែលហៅថាសេវាសង្គម ?

- ✓ សេវាសង្គម គឺជាអ្វីៗ គ្រប់បែបយ៉ាងដែលសង្គមបានផ្តល់ឱ្យជាសាធារណៈ សម្រាប់ប្រើប្រាស់ និងសម្រាប់ទ្រទ្រង់ដល់ការរស់នៅ និងសម្រាប់ធានាសុខមាលភាពរស់នៅរបស់ប្រជាជន។
- ✓ សេវាសង្គមរួមមាន ២ ប្រភេទគឺ ៖
  - សេវាសាធារណៈ
  - សេវាមូលដ្ឋាន

# តើសេវាសាធារណៈគឺជាអ្វី ?

✓ សេវាសាធារណៈ គឺជាសេវាកម្មដែលបានផ្តល់ដោយដោយរដ្ឋាភិបាល ទៅកាន់ប្រជាជនដែលរស់នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន ដោយផ្ទាល់ (តាមរយៈវិស័យសាធារណៈ) ឬដោយការផ្តល់ជាហិរញ្ញវត្ថុដល់ផ្នែកឯកជនក្នុងការផ្តត់ផ្គង់សេវានោះ ។

# សេវាសាធារណៈ











សាលារៀន

មន្ទីរពេទ្យ

បង្គន់សាធារណៈ

ផ្លូវថ្នល់

បណ្ដាញទូរគមនាគមន៍



# សេវាមូលដ្ឋានរួមមាន

- បណ្តាញលូទឹកស្អុយ
- បណ្តាញទឹកស្អាត
- បណ្តាញអគ្គិសនី
- អណ្តូង បង្គន់អនាម័យ ផ្ទះសំបែង
- វត្ថុសម្រាប់ដុត..... ។



# ការផ្តល់សេវាសង្គម (សេវាសាធារណៈ និងសេវាមូលដ្ឋាន) ដល់ប្រជាជនបានគ្រប់គ្រាន់បានផ្តល់នូវគុណសម្បត្តិជាច្រើនដូចជា៖

- ធ្វើឱ្យអាយុសង្ឃឹមរស់របស់មនុស្សកើនឡើង
- កាត់បន្ថយនូវអត្រាមរណភាពមាតា និងកុមារ
- កាត់បន្ថយនូវការឆ្លងជំងឺផ្សេងៗដូចជា រាក គ្រុនចាញ់ និងអាសន្នរោគជាដើម



# ការផ្តល់សេវាសង្គម (សេវាសាធារណៈ និងសេវាមូលដ្ឋាន) ដល់ប្រជាជនបានគ្រប់គ្រាន់បានផ្តល់នូវគុណសម្បត្តិជាច្រើនដូចជា៖

- កាត់បន្ថយនូវគ្រោះថ្នាក់របស់មាតា និងទារកក្នុងផ្ទៃ
- ប្រជាជនមានសុខភាពល្អ
- ប្រជាជនមានកម្លាំងមាំមួនក្នុងការបំពេញការងារ
- កាត់បន្ថយនូវការចំណាយទាំងថវិកាគ្រួសារ និងថវិកាជាតិលើការព្យាបាលជំងឺផ្សេងៗ ។

## ជាទូទៅ ការប្រើប្រាស់សេវាសង្គម (សេវាសាធារណៈ និងសេវាមូលដ្ឋាន) នៅទីក្រុង ឬទីប្រជុំជន និងជនបទមាន លក្ខណៈមិនដូចគ្នានោះទេ ពីព្រោះ ៖

- សេដ្ឋកិច្ចទីក្រុង ឬប្រជុំជន គឺមានកម្រិតខ្ពស់ជាងជនបទ ដូចនេះប្រជាជនក្រុងមានលទ្ធភាពប្រើប្រាស់សេវានេះបានច្រើនជាងជនបទ
- ទីក្រុង ជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំទៅដោយគ្រប់សកម្មភាពទាំងអស់របស់ប្រទេស ដូចនេះប្រជាជនក្រុងមាន កម្រិតជីវភាពរស់នៅខ្ពស់ជាងប្រជាជនបទ ដែលនាំឱ្យគេមានលទ្ធភាពប្រើប្រាស់សេវានេះបានល្អជាងប្រជាជននៅជនបទ។

## ជាទូទៅ ការប្រើប្រាស់សេវាសង្គម (សេវាសាធារណៈ និងសេវាមូលដ្ឋាន) នៅទីក្រុង ឬទីប្រជុំជន និងជនបទមាន លក្ខណៈមិនដូចគ្នានោះទេ ពីព្រោះ ៖

- ទីក្រុងជាមជ្ឈមណ្ឌលនយោបាយ វប្បធម៌ និងនយោបាយរបស់ប្រទេស ដូចនេះទីក្រុងមានកម្រិតអភិវឌ្ឍន៍ជាងជនបទ ដែលនាំឱ្យទីក្រុងមានសេវាទាំងនេះដ៏សម្បូរបែបជាងជនបទ និងមានតម្លៃថោកជាងជនបទ ដែលបង្កលក្ខណៈងាយស្រួលឱ្យប្រជាជនក្រុងមានលទ្ធភាពប្រើប្រាស់ច្រើនជាងប្រជាជនជនបទ។
- ទីក្រុងប្រមូលផ្ដុំទៅដោយផ្លូវគមនាគមន៍ ដែលបង្កលក្ខណៈងាយស្រួលឱ្យប្រជាជនក្រុងទទួលយកសេវាទាំងនេះជាងតំបន់ជនបទ។



# លទ្ធភាពក្នុងការប្រើប្រាស់ទឹកស្អាត

# ជាទូទៅ លទ្ធភាពប្រើប្រាស់ទឹកស្អាតរបស់ប្រជាជនកម្ពុជាបាននាំមកនូវសារៈប្រយោជន៍ជាច្រើនដូចជា ៖

- ប្រជាជនមានសុខភាពល្អប្រសើរ
- កាត់បន្ថយអត្រាមរណភាពមាតា និងកុមារ
- អាយុសង្ឃឹមរស់ប្រជាជនកើនឡើង ប្រជាជនមិនឆ្លងនូវជម្ងឺផ្សេងៗ
- មានកំណើនសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ
- ប្រជាជនមានកម្លាំងគ្រប់គ្រាន់ ក្នុបការបំពេញការងារប្រចាំថ្ងៃ។

# អនាម័យមូលដ្ឋាន

# ការបន្ទោរបង់ពាសវាលពាសកាលរបស់ប្រជាជនបង្កឲ្យមានផលប៉ះពាល់៖

**ផលប៉ះពាល់ដូចជា**

- សុខភាពមនុស្ស
- សង្គម
- សេដ្ឋកិច្ច
- បរិស្ថាន



# ផលប៉ះពាល់ដល់សុខភាពមនុស្ស

- បង្កឱ្យមានជម្ងឺរាគរូស
- បង្កឱ្យមានជម្ងឺអាសន្នរោគ
- បង្កឱ្យមានជម្ងឺរលាកថ្លើម
- បង្កឱ្យមានជម្ងឺប្រព័ន្ធផ្លូវដង្ហើម
- បង្កឱ្យមានជម្ងឺវិលមុខ ក្អួតចង្អោរ។





# ផលប៉ះពាល់លើសេដ្ឋកិច្ច និងសង្គម

- បង្កឱ្យសង្គមមានកេរ្តិ៍ឈ្មោះមិនល្អ
- បង្កឱ្យបាត់បង់ភ្ញៀវទេសចរ
- បង្កឱ្យបាត់បង់ចំណូលថវិកាជាតិ តាមរយៈការបាត់បង់ភ្ញៀវទេសចរ
- បង្កឱ្យប្រជាជនបាត់ការងារ និងបាត់បង់ចំណូលថវិកាគ្រួសារ តាមរយៈភ្ញៀវទេសចរធ្លាក់ចុះ។



# ផលប៉ះពាល់លើបរិស្ថាន

- បង្កឱ្យមានការបំពុលខ្យល់
- បង្កឱ្យមានការបំពុលទឹក
- បង្កឱ្យមានការបាត់បង់សោភ័ណភាពធម្មជាតិ ។



# ពង្រឹងពុទ្ធិ

# តើការបន្ទោរបង់ពាសវាលពាសកាលរបស់ប្រជាជន បង្កឱ្យមានផលប៉ះពាល់អ្វីខ្លះ ?

<u>ចម្លើយជ្រើសរើស</u>

✗ ក. ផលប៉ះពាល់លើសុខភាពមនុស្ស

✗ ខ. ផលប៉ះពាល់ លើសេដ្ឋកិច្ច និងសង្គម

✗ គ. ផលប៉ះពាល់ លើបរិស្ថាន

✓ ឃ. ចម្លើយទាំងអស់

# ដូចម្ដេចដែលហៅថា សេវាសង្គម ?

## ចម្លើយជ្រើសរើស

✓ ក. ជាអ្វីៗ គ្រប់បែបយ៉ាង ដែលសង្គមបានផ្ដល់ឱ្យជាសាធារណៈ សម្រាប់ប្រើប្រាស់ និងសម្រាប់ទ្រទ្រង់ដល់ការរស់នៅ

✗ ខ. ជាសេវាដែលបម្រើឱ្យការប្រើប្រាស់ជាសាធារណៈ និងមិនសម្រាប់ទ្រទ្រង់ដល់ការរស់នៅ

✗ គ. ចម្លើយ ក និង ខ

# តើសេវាមូលដ្ឋានរួមមានអ្វីខ្លះ ?

**សេវាមូលដ្ឋានរួមមាន**

- បណ្តាញលូទឹកស្អុយ
- បណ្តាញទឹកស្អាត
- បណ្តាញអគ្គិសនី
- អណ្តូង បង្គន់អនាម័យ ផ្ទះសំបែង
- វត្ថុសម្រាប់ដុត..... ។

# សូមអរគុណ !!

ប្រឹងប្រែងរៀនដើម្បី អនាគតខ្លួនឯង ជួយខ្លួនឯង គ្រួសារ និង សង្គមជាតិ

